# ការយល់ឃើញរបស់សាធារណជនអំពីសេរីភាពជាមូលដ្ឋានក្នុងប្រទេសកម្ពុជា៖ ការវិវឌ្ឍរយៈពេល៥ ឆ្នាំ

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន ជាគម្រោង[1]ឃ្លាំមើលលំហសង្គមស៊ីវិលនៅប្រទេសកម្ពុជា រួមទាំងលទ្ធភាពក្នុងការយល់ដឹង និងការអនុវត្តសេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ (សេរីភាពមូលដ្ឋាន)។ ជារៀងរាល់ឆ្នាំ[2]គម្រោងបានធ្វើការស្ទង់មតិជាសាធារណៈដើម្បីពិនិត្យពីការយល់ដឹងអំពីសេរីភាពមូលដ្ឋាន និងថាតើពួកគេមានសេរីភាពក្នុងការអនុវត្តសិទ្ធិរបស់ពួកគេដែរឬណា។ គម្រោងបានប្រើប្រាស់សំណាកងាយៗគ្រប់ខេត្តទាំងអស់ក្នុងប្រទេសកម្ពុជា ដើម្បីធ្វើការស្ទង់មតិជារៀងរាល់ឆ្នាំ ដែលមានគោលដៅចាប់យកក្រុមអាយុ និងចំនួនអ្នកឆ្លើយតបបុរសនិងស្ត្រីស្មើគ្នា។

ការឆ្លើយតបពីពលរដ្ឋប្រមាណ ១,០០០ នាក់ត្រូវបានកត់ត្រាទុកជារៀងរាល់ឆ្នាំ។ អ្នកឆ្លើយតបមានចំនួនតិចនៅឆ្នាំទី៤ និងទី៥ ដោយសារបញ្ហាប្រឈមនៃការចុះប្រមូលទិន្នន័យដោយផ្ទាល់នៅនឹងកន្លែង ដោយសារស្ថានភាពរាតត្បាតជំងឺកូវីដ-១៩ ។




## ការយល់ដឹងអំពីសេរីភាពជាមូលដ្ឋាន

តួលេខបានបង្ហាញពីការយល់ដឹងតិចតួចអំពីសេរីភាពខាងសមាគម ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ប៉ុន្តែនៅឆ្នាំទី៥ មានភាពប្រសើរឡើង ។ អ្នកឆ្លើយតបនៅក្នុងឆ្នាំទី៥នេះ មានការយល់ដឹងអំពីសេរីភាពមូលដ្ឋានទាំងអស់ជាងឆ្នាំមុនៗ។

*ភាគរយនៃអ្នកឆ្លើយតបដែលបានឆ្លើយថាពួកគេមានការយល់ដឹងខ្លះអំពីសេរីភាព...*




## កម្រិតដែលបុគ្គលនីមួយៗមានការយល់ដឹងថាមានសេរីភាពក្នុងការអនុវត្តសេរីភាពមូលដ្ឋាន

សេរីភាពក្នុងការបញ្ចេញមតិជាសាធារណៈ៖ ភាគរយនៃអ្នកឆ្លើយតបដែលយល់ថា "មានសេរីភាពខ្លាំងណាស់" ឬ "មានសេរីភាពខ្លះដែរ" ក្នុងការនិយាយដោយបើកចំហនៅទីសាធារណៈបានបន្តធ្លាក់ចុះ។

សេរីភាពក្នុងការចូលរួមសកម្មភាពនយោបាយ៖ ភាគរយនៃអ្នកឆ្លើយតបដែលយល់ថា "មានសេរីភាពខ្លាំងណាស់" ឬ




"មានសេរីភាពខ្លះ" ក្នុងការចូលរួមសកម្មភាពនយោបាយបានថយចុះ។




---

[1] ឆ្នាំទី ១ ចាប់ពីខែមេសា ឆ្នាំ២០១៦ ដល់ខែមីនា ឆ្នាំ២០១៧; ឆ្នាំទី២ ចាប់ពីខែមេសា ឆ្នាំ២០១៧ ដល់ខែមីនា ឆ្នាំ២០១៨; ឆ្នាំទី ៣ ចាប់ពីខែមេសា ឆ្នាំ២០១៨ ដល់ខែមីនា ឆ្នាំ២០១៩; ឆ្នាំទី៤ ចាប់ពីខែមេសា ឆ្នាំ២០១៩ ដល់ខែមីនា ឆ្នាំ២០២០; និងឆ្នាំទី៥ ចាប់ពីខែមេសា ឆ្នាំ២០២០ ដល់ខែធ្នូ ឆ្នាំ២០២០។

[2] ការស្ទង់មតិសាធារណៈត្រូវបានធ្វើឡើងក្នុងខែតុលា ឆ្នាំ ២០១៦ (ឆ្នាំទី១) ខែមីនា ឆ្នាំ២០១៦ (ឆ្នាំទី២) ខែមីនា ឆ្នាំ ២១០៩ (ឆ្នាំទី៣) ខែមីនា ឆ្នាំ ២០២០ (ឆ្នាំទី៤) និងខែធ្នូ ឆ្នាំ២០២០ (ឆ្នាំទី៥)។

សេរីភាពក្នុងការធ្វើកូដកម្មដោយសន្តិវិធី ៖ ចំនួននៃអ្នកឆ្លើយតបដែលយល់ថា "មានសេរីភាពខ្លាំងណាស់" ក្នុងការធ្វើកូដកម្មដោយសន្តិវិធី មានការប្រែប្រួលក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ដោយឈានដល់កម្រិតខ្ពស់បំផុតនៅឆ្នាំទី៥។




## សមត្ថភាពនៃបុគ្គលនីមួយៗដើម្បីកំណត់ដែនកំណត់នៃសិទ្ធិរបស់ខ្លួន

សមត្ថភាពរបស់បុគ្គលក្នុងការអនុវត្តសេរីភាពមូលរបស់ពួកគេគឺពឹងផ្អែកលើការយល់ដឹងរបស់ពួកគេអំពីច្បាប់ជាតិនិងច្បាប់ពាក់ព័ន្ធដែលបានឆ្លើយតប។ ដើម្បីវាយតម្លៃថាតើពលរដ្ឋពិតជាយល់ដឹងអំពីសិទ្ធិរបស់ខ្លួននិងដែនកំណត់នៃសិទ្ធិទាំងនេះ អ្នកឆ្លើយតបត្រូវបានសួរជារៀងរាល់ឆ្នាំដើម្បីកំណត់ថាតើសកម្មភាពណាខ្លះស្របច្បាប់ ឬខុសច្បាប់។

សេរីភាពខាងការបញ្ចេញមតិ៖ ប៉ុន្មានឆ្នាំកន្លងមកនេះ អ្នកឆ្លើយតបភាគច្រើនបានឆ្លើយយ៉ាងត្រឹមត្រូវថា ជាការខុសច្បាប់ក្នុងការប្រមាថដល់បុគ្គលសាធារណៈ។ ទោះជាយ៉ាងណាក៏ដោយ មានអ្នកឆ្លើយតបតិចតួចបានឆ្លើយត្រឹមត្រូវថា ការរិះគន់គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និង ជជែកពីនយោបាយជាមួយអ្នកដទៃជារឿងស្របច្បាប់។




សេរីភាពខាងសមាគម៖ ជារៀងរាល់ឆ្នាំអ្នកឆ្លើយតបភាគច្រើនបានឆ្លើយយ៉ាងត្រឹមត្រូវថា ការបង្កើតអង្គការមិនមែនរដ្ឋាភិបាលដែលមិនបានចុះបញ្ជីគឺជារឿងខុសច្បាប់ ប៉ុន្តែមានមនុស្សតិចណាស់ដែលឆ្លើយត្រឹមត្រូវថាជារឿងស្របច្បាប់ក្នុងការធ្វើសកម្មភាពខាងសមាគមដោយគ្មានការជូនដំណឹងដល់អាជ្ញាធរ។




សេរីភាពខាងការជួបប្រជុំ៖ ភាគរយនៃអ្នកឆ្លើយតបដែលអាចឆ្លើយបានត្រឹមត្រូវថាស្របច្បាប់ក្នុងការតវ៉ាដោយសន្តិវិធីនៅតែមានកម្រិតទាបក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ដែលឈានដល់ជាង៥០% នៅលើកដំបូងក្នុងឆ្នាំទី៥។ អ្នកឆ្លើយតបតិចជាងមួយភាគបីនៃអ្នកឆ្លើយតបជារៀងរាល់ឆ្នាំ បានឆ្លើយថាការធ្វើកូដកម្មដោយគ្មានការអនុញ្ញាតគឺជារឿងស្របច្បាប់។




## ភាពខុសគ្នារវាងយេនឌ័រ

អ្នកឆ្លើយតបជាបុរសច្រើនជាងអ្នកឆ្លើយតបជាស្ត្រីបានឆ្លើយដូចៗគ្នាថាថាពួកគេមានអារម្មណ៍"មានសេរីភាពខ្លះដែរ" ឬ "មានសេរីភាពខ្លាំងណាស់" ក្នុងការនិយាយនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមក្នុងរយៈពេលជាច្រើនឆ្នាំ។ ប៉ុន្តែ ចំនួននេះនៅតែបន្តធ្លាក់ចុះទាំងអ្នកឆ្លើយតបជាបុរស និងជាស្ត្រី។




បុរសច្រើនជាងស្ត្រីបានឆ្លើយថា ពួកគេមានអារម្មណ៍ "មានសេរីភាពខ្លាំងណាស់" ឬ "មានសេរីភាពខ្លះដែរ" ក្នុងការចូលរួមសកម្មភាពនយោបាយក្នុងរយៈពេលជាច្រើនឆ្នាំ។ ប៉ុន្តែចំនួននេះនៅតែបន្តធ្លាក់ចុះទាំងអ្នកឆ្លើយតបជាបុរសនិងស្ត្រី។




ខែវិច្ឆិកា ឆ្នាំ២០២១